https://www.facebook.com/Voangeksa

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធការប្រឆាំងអំពើពុករលួយ

អង្គភាពប្រឆាំងអំពើពុករលួយ

វ៉ាំងឯកសារ

https://www.facebook.com/Voangeksa

## ព្រះរាជក្រម

នស/រកម/០៤១០/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១០/០០៣/២០១០ កបធ.ច ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

https://www.facebook.com/Voangeksa

# ច្បាប់

# ស្តីពី

# ការប្រឆាំងអំពើពុករលួយ

https://www.facebook.com/Voangeksa

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.– គោលបំណង**

ច្បាប់នេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពសេវាគ្រប់បែបយ៉ាង ពង្រឹងអភិបាលកិច្ច និង នីតិរដ្ឋនៅក្នុងការដឹកនាំនិងការគ្រប់គ្រងរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និង យុត្តិធម៌ដែលជាមូលដ្ឋានចាំបាច់ក្នុងការអភិវឌ្ឍសង្គមជាតិ និង កាត់បន្ថយភាពក្រីក្រ ។

**មាត្រា ២.– គោលដៅ**

ច្បាប់នេះ មានគោលដៅប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈការចាត់វិធានការអប់រំ បង្ការទប់ស្កាត់ និង អនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ ហើយដោយមានការចូលរួម និង គាំទ្រពីមហាជននិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣.– វិសាលភាព**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និង គ្រប់ជាន់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តក្រោយពេលដែលច្បាប់នេះមានអានុភាពអនុវត្ត ។

**មាត្រា ៤.– និយមន័យ**

វាក្យសព្ទបច្ចេកទេសក្នុងច្បាប់នេះមានន័យដូចតទៅ :

១- **បទល្មើសពុករលួយ** មានន័យថា បទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

២- **អ្នករាជការសាធារណៈ** មានន័យថា :

ក- បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬ ជាបណ្តោះអាសន្នក្តី ទោះជាបាន ឬ មិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុរបស់បុគ្គលនោះឡើយ ។

https://www.facebook.com/Voangeksa

២- បុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬ សហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

៣- **មន្ត្រីសាធារណៈបរទេស** មានន័យថា មន្ត្រីបរទេសដែលកាន់តំណែងក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការរបស់ប្រទេសក្រៅនោះជាបានតែងតាំង ឬ បោះឆ្នោតជ្រើសរើសក៏ដោយ និង ជនបរទេសដែលអនុវត្តមុខងារសាធារណៈសម្រាប់ប្រទេសក្រៅណាមួយ រួមមានទីភ្នាក់ងារសាធារណៈ ឬ សហគ្រាសសាធារណៈ ។

៤- **មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ** មានន័យថា មន្ត្រីអន្តរជាតិ ឬ ជនណាដែលទទួលបានការអនុញ្ញាតពីអង្គការអន្តរជាតិឱ្យបំពេញភារកិច្ច ក្នុងនាមអង្គការអន្តរជាតិនោះ ។

៥- **ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត** មានន័យថា សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

៦- **ចៅក្រម** មានន័យថា ចៅក្រមអាសនៈ និង ចៅក្រមអយ្យការ ។

៧- **នីតិបុគ្គល** មានន័យថា ក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច ។

៨- **សង្គមស៊ីវិល** មានន័យថា សហគមន៍ ឬ ក្រុមមនុស្សដែលបង្កើតឡើងដើម្បីធ្វើសកម្មភាពក្នុងការការពារផលប្រយោជន៍លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ វិទ្យាសាស្ត្រ វប្បធម៌ និង សាសនា មានជាអាទិ៍ សមាគម អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ ។

៩- **អត្ថប្រយោជន៍** មានន័យថា :

ក- អំណោយអ្វីមួយ កម្រៃ តម្លៃឈ្នួល រង្វាន់ ឬ កម្រៃជើងសាដែលមិនមានការអនុញ្ញាតដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬ ជាវត្ថុមានតម្លៃ ឬ ជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ ។

ខ- ការងារ តំណែង មុខងារ កិច្ចព្រមព្រៀង ឬ កិច្ចសន្យាអ្វីមួយ ។

គ- ការបង់ប្រាក់ ការលើកលែង ការលុបចោល ការលុបបំបាត់នូវប្រាក់កម្ចីអ្វីមួយ កាតព្វកិច្ច ឬ បំណុលផ្សេងទៀត ទោះជាទាំងមូលក្តី ឬ ដោយផ្នែកក្តី ។

ឃ- សេវាកម្មឯទៀត ឬ ការផ្តល់ជាគុណប្រយោជន៍ រួមទាំងកិច្ចការពារមិនឱ្យមានការដាក់ទណ្ឌកម្ម ដែលលេចចេញពីអំពើ ឬ ដំណើរការនៃការដាក់ទណ្ឌកម្មរដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ទោះបីទណ្ឌកម្មនេះ ត្រូវបានកំណត់ ឬ ពុំទាន់ត្រូវបានកំណត់ក៏ដោយ ។

ង- ការអនុវត្ត ឬ ការរារាំងមិនឱ្យអនុវត្តនូវសិទ្ធិ ឬ អំណាច ឬ ភារកិច្ចអ្វីមួយ ។

ច-ការស្នើជូន ឬ ការសន្យាថាជូន ទោះបីមានលក្ខខណ្ឌ ឬ គ្មានលក្ខខណ្ឌក្តី នូវអត្ថប្រយោជន៍ ដូចមានចែងក្នុងស្មារតីនៃកថាខណ្ឌ (ក) (ខ) (គ) (ឃ) និង(ង) ។

១០- **អំណោយ** មានន័យថា ទ្រព្យ ឬ សេវាដែលត្រូវបានផ្តល់ឱ្យទៅបុគ្គលណាម្នាក់ ឬ ដើម្បីជាប្រយោជន៍ដល់បុគ្គលណាម្នាក់ ហើយដែលមិនត្រូវបានចាត់ទុកជាកិច្ចព្រមព្រៀង និង មិនមែនជាជំនូនតាមទំនៀមទម្លាប់ ឬ ប្រពៃណី ។

១១- **ទំនាស់ផលប្រយោជន៍** មានន័យថា ផលប្រយោជន៍ជាទឹកប្រាក់ ផលប្រយោជន៍នយោបាយ ផលប្រយោជន៍សម្រាប់គ្រួសារ ឬ ផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចមានឥទ្ធិពលលើទង្វើរបស់ជនណាម្នាក់ ក្នុងការអនុវត្តកាតព្វកិច្ចជាផ្លូវការរបស់ខ្លួន ។

១២- **ទ្រព្យសម្បត្តិ** មានន័យថា ទ្រព្យគ្រប់ប្រភេទ ទោះជាចលនវត្ថុ ឬ ជាអចលនវត្ថុ រូបីយ ឬ អរូបីយ និង ឯកសារគតិយុត្ត ឬ លិខិតូបករណ៍ដែលបញ្ជាក់ពីកម្មសិទ្ធិ ឬ ផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិនោះ ។

១៣- **ការទប់យក** មានន័យថា ការហាមប្រាមជាបណ្តោះអាសន្នមិនឱ្យធ្វើការផ្ទេរ ផ្លាស់ប្តូរ ប្រែប្រួល ប្រគល់ឱ្យ ឬ ធ្វើចលនានៃទ្រព្យសម្បត្តិ ឬ យកធ្វើជាទ្រព្យសម្បត្តិបណ្តោះអាសន្ន ឬ គ្រប់គ្រងទ្រព្យសម្បត្តិ តាមរយៈដីកាតុលាការ ។

១៤- **ការរឹបអូស** មានន័យថា ការដកហូតជាអចិន្ត្រៃយ៍នូវទ្រព្យសម្បត្តិណាមួយ តាមរយៈសេចក្តីសម្រេចរបស់តុលាការ ។

១៥- **ផលនៃអំពើពុករលួយ** មានន័យថា ទ្រព្យណាក៏ដោយដែលបានមកពី ឬ ទទួលបានដោយផ្ទាល់ ឬ ដោយប្រយោល តាមរយៈការប្រព្រឹត្តអំពើពុករលួយ ។

១៦- **កម្រៃ** មានន័យថា ផលជាប្រាក់បានមកអំពីកិច្ចការការិយាល័យ ឋានៈ មុខងារ ឬ ការងារ ដែលរួមទាំងប្រាក់បៀវត្ស ប្រាក់ឈ្នួល និង ប្រាក់បន្ថែមឯទៀត ។

១៧- **ការប៉ុនប៉ង** មានន័យថា ការប្រព្រឹត្តអំពើពុករលួយដែលអាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះ ត្រូវបានបំពេញ :

ក- ចារីបានចាប់ផ្តើមប្រព្រឹត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស និង

ខ- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តតែត្រូវបានរាំងស្ទះ ឬ អាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។ អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមប្រព្រឹត្តទេ ។

១៨- **អ្នកផ្តើមគំនិត** មានន័យថា បុគ្គលណាដែល :

ក- ជម្រុញឱ្យប្រព្រឹត្តបទល្មើសពុករលួយតាមការណែនាំ ឬ បញ្ជា ។

ខ- បង្កឱ្យមានបទល្មើសពុករលួយ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

១៩- **អ្នកសមគំនិត** មានន័យថា បុគ្គលដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬ ការសម្រេចបទល្មើសពុករលួយដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន ។

២០- **អង្គភាពដើមប្រឆាំងអំពើពុករលួយ** មានន័យថា អង្គភាពប្រឆាំងអំពើពុករលួយដែលត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៦ ។

## ជំពូកទី ២

## ស្ថាប័នប្រឆាំងអំពើពុករលួយ

**មាត្រា ៥.- ស្ថាប័នប្រឆាំងអំពើពុករលួយ**

ស្ថាប័នប្រឆាំងអំពើពុករលួយរួមមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង

https://www.facebook.com/Voangeksa

អង្គភាពប្រឆាំងអំពើពុករលួយ ។

ស្ថាប័នប្រឆាំងអំពើពុករលួយមានឲ្យបសញ្ញា និង ត្រាសម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួនដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ១

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

**មាត្រា ៦.- ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដែលមានតួនាទីពិគ្រោះយោបល់ និង ផ្តល់អនុសាសន៍លើការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានសមាជិក ១១ (ដប់មួយ) រូប ដែលមានសមាសភាពដូចខាងក្រោម៖

១- តំណាងរាស្ត្រ ១ (មួយ) រូប តែងតាំងដោយព្រះមហាក្សត្រ ។

២- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងដោយព្រឹទ្ធសភា តាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

៣- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋសភា តាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

៤- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងចេញពីរាជរដ្ឋាភិបាល ។

៥- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីអាជ្ញាធរសវនកម្មជាតិ ។

៦- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ។

៧- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីក្រុមប្រឹក្សាអ្នកច្បាប់ ។

៨- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ។

៩- តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

១០-តំណាងរាស្ត្រ ១ (មួយ) រូប ជ្រើសតាំងចេញពីគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ។

១១- ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។

សមាជិកនីមួយៗ នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ត្រូវមានលក្ខណសម្បត្តិដូចតទៅ :

- មានសញ្ញាតិខ្មែរពីកំណើត
- មានសីលធម៌ល្អ និង មានកេរ្តិ៍ឈ្មោះស្អាតស្អំ
- មិនដែលមានទោសមជ្ឈិម ឬ ឧក្រិដ្ឋ ឬ មិនមានក្ស័យធន
- មានសញ្ញាបត្រចាប់ពីឧត្តមសិក្សាឡើងទៅ
- មានបទពិសោធន៍ការងារក្នុងសង្គមយ៉ាងតិច ១០ (ដប់) ឆ្នាំ
- មានអាយុយ៉ាងតិច ៤៥ (សែសិបប្រាំ) ឆ្នាំ ។

**មាត្រា ៧.- អាណត្តិ ការដកចេញពីតំណែង និង ការជំនួសតំណែង**

សមាជិកទាំងអស់នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ។ អាណត្តិនេះអាចត្រូវបន្តជាថ្មី ។

ក្នុងករណីសមាជិកណាម្នាក់នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ទទួលមរណ-ភាព លាលែងចេញពីតំណែង ឬ ត្រូវបានបណ្តេញចេញពីមុខតំណែង ឬ មិនអាចបំពេញមុខតំណែងរបស់ខ្លួនបានដោយប្រការណាមួយចាប់ពី ៦ (ប្រាំមួយ) ខែឡើងទៅមុនពេលបញ្ចប់អាណត្តិ សមាជិកថ្មីត្រូវបានតែងតាំងជំនួស ។

តំណែងរបស់សមាជិកនៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយណាក៏ដោយ នឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិនៅពេលដែលតុលាការសម្រេចថា សមាជិកនោះមានទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋណាមួយ ។

ក្នុងករណីទាំងឡាយខាងលើនេះ ប្រធានត្រូវកោះប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដើម្បីសម្រេច និង ដាក់វិធានការសមស្របពាក់ព័ន្ធនឹងការបញ្ចប់តំណែង ការដកហូតតំណែង ព្រមទាំងការជ្រើសតាំងតំណាងរាស្ត្រជំនួស ស្របតាមមាត្រា ៦ (ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ) នៃច្បាប់នេះ ។

**មាត្រា ៨.– ការជ្រើសតាំងប្រធាន និង អនុប្រធាន**

ប្រធាន និង អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយត្រូវជ្រើសតាំងដោយការបោះឆ្នោតពីសមាជិករបស់ខ្លួនតាមសំឡេងភាគច្រើនដាច់ខាត ដែលត្រូវធ្វើឡើងក្នុងសម័យប្រជុំលើកទី ១ តាមការកោះអញ្ជើញរបស់សមាជិក ដែលមានវ័យចាស់ជាងគេ ។ ក្នុងករណីបោះឆ្នោតលើកទី ១ ពុំបានសម្រេច ការបោះឆ្នោតលើកទី ២ ត្រូវយកមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអវត្តមាន ឬ មិនអាចបំពេញភារកិច្ចបាន អនុប្រធានបំពេញភារកិច្ចជំនួស ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមិនអាចឈរឈ្មោះជាប្រធាន ឬ អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយបានឡើយ ។

**មាត្រា ៩.– ឋានៈរបស់សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានឋានៈ ដូចខាងក្រោម :

- ប្រធាន មានឋានៈស្មើឧបនាយករដ្ឋមន្ត្រី
- អនុប្រធាន មានឋានៈស្មើទេសរដ្ឋមន្ត្រី
- សមាជិក មានឋានៈស្មើរដ្ឋមន្ត្រី ។

**មាត្រា ១០.– ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានភារកិច្ចដូចតទៅ :

- កសាងយុទ្ធសាស្ត្រ និង គោលនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ពិគ្រោះយោបល់ និង ផ្តល់អនុសាសន៍ដល់អង្គភាពប្រឆាំងអំពើពុករលួយពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ឃ្លាំមើលដំណើរការការងារនៃអង្គភាពប្រឆាំងអំពើពុករលួយ
- ស្នើអង្គភាពប្រឆាំងអំពើពុករលួយឱ្យរាយការណ៍ ឬ បំភ្លឺ
- ធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រី អំពីដំណើរការរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍ប្រចាំឆមាស និង ប្រចាំឆ្នាំជូននាយករដ្ឋមន្ត្រី
- រៀបចំ និង អនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

https://www.facebook.com/Voangeksa

## ជំពូកទី ២
## អង្គភាពប្រឆាំងអំពើពុករលួយ

**មាត្រា ១១.- ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ**

ត្រូវបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ដែលមានឯករាជ្យភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

អង្គភាពប្រឆាំងអំពើពុករលួយដឹកនាំដោយប្រធាន ១ (មួយ) រូប មានឋានៈស្មើទេសរដ្ឋមន្ត្រី និង អនុប្រធានមួយចំនួនមានឋានៈស្មើរដ្ឋមន្ត្រីជាជំនួយការតាមការចាំបាច់ ។

ប្រធាន និង អនុប្រធានត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.- លក្ខណសម្បត្តិនៃប្រធាន និង អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**

ប្រធាន និង អនុប្រធានត្រូវមានលក្ខណសម្បត្តិដូចតទៅ :

- មានសញ្ជាតិខ្មែរពីកំណើត
- មានសីលធម៌ល្អ និង កេរ្តិ៍ឈ្មោះស្អាតស្អំ
- មិនដែលមានទោសមជ្ឈិម ឬ ឧក្រិដ្ឋ ឬ មិនមានក្ស័យធន
- មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ
- មានបទពិសោធន៍ការងារក្នុងសង្គមយ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ
- មានអាយុយ៉ាងតិច ៣៥ (សាមសិបប្រាំ) ឆ្នាំ ។

**មាត្រា ១៣.- ភារកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ**

អង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចដូចខាងក្រោម :

- អនុវត្តច្បាប់ បទបញ្ជា និង បទប្បញ្ញត្តិពាក់ព័ន្ធនឹងបទល្មើសពុករលួយជា

https://www.facebook.com/Voangeksa

- រៀបចំកសាងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយស្របតាមយុទ្ធសាស្ត្រ និង នយោបាយរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
- ដឹកនាំការងារទប់ស្កាត់ និង បង្ក្រាបអំពើពុករលួយ
- តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និង ធ្វើការសិក្សាស្រាវជ្រាវព្រមទាំងលើកវិធានការនានា ពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និង ឯកជនទាំងអស់ស្របតាមនីតិវិធីជាធរមាន
- ទទួល និង ពិនិត្យរាល់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន
- ស្វែងរក ពិនិត្យ និង រៀបចំឯកសារ និង ព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ
- រក្សាការសម្ងាត់ជាដាច់ខាតចំពោះប្រភពព័ត៌មានទាក់ទងនឹងអំពើពុករលួយ
- ចាត់វិធានការចាំបាច់ដើម្បីរក្សាសន្តិសុខដល់បុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ
- ធ្វើការគ្រប់គ្រងប្រព័ន្ធការប្រកាសទ្រព្យសម្បត្តិ និង បំណុលដូចមានបញ្ញត្តក្នុងច្បាប់នេះ
- ដឹកនាំការងារឃោសនាអប់រំមហាជនអំពីផលវិបាកនៃអំពើពុករលួយ និងលើកទឹកចិត្តឱ្យមហាជនចូលរួមក្នុងការបង្ការទប់ស្កាត់ និង កម្ចាត់អំពើពុករលួយ
- ពិនិត្យ និង លើកគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ទទួលឆ្លើយបំភ្លឺដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរចំពោះរាល់សំណួរដែលលើកឡើងដោយសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ឬ សមាជិករដ្ឋសភា
- បម្រើសេវាការងារជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
- តែងតាំង ផ្លាស់ប្តូរ និង គ្រប់គ្រង ឬ លើកសំណើតែងតាំង ផ្លាស់ប្តូរ មន្ត្រីរាជការក្រោមឱវាទក្នុងអង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការតំបន់ អង្គការអន្តរជាតិនានា ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយឆ្លងដែន

https://www.facebook.com/Voangeksa

- ធ្វើរបាយការណ៍អំពីសកម្មភាពទាំងឡាយរបស់អង្គភាពប្រឆាំងអំពើពុករលួយ ជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

- មានសិទ្ធិធ្វើការព្រមានចំពោះមុខសញ្ញាដែលក្នុងដំណាក់កាលដំបូងមានការខកខានមិនបានអនុវត្តច្បាប់ និង បទប្បញ្ញត្តិជាធរមាន ក្នុងគោលដៅបង្ការនិងទប់ស្កាត់អំពើពុករលួយ ។

**មាត្រា ១៤.- មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ**

មន្ត្រីបម្រើការងារនៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយរួមមាន មន្ត្រីរាជការដែលត្រូវបានតែងតាំង ឬ ផ្ទេរ ឬ បញ្ជូនមកបម្រើការងារក្នុងអង្គភាព និង មន្ត្រីដែលត្រូវបានជ្រើសរើសឱ្យមកបម្រើការងារតាមកិច្ចសន្យា ។ មន្ត្រីទាំងអស់ខាងលើនេះត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធដទៃទៀតជាធរមាន ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចជ្រើសរើសអ្នកជំនាញការ អ្នកឯកទេស និង អ្នកស្រាវជ្រាវជាតិ អន្តរជាតិ ជាប់កិច្ចសន្យា ឬ ដោយស្ម័គ្រចិត្តឱ្យមកជួយផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធការប្រឆាំងអំពើពុករលួយ។

**មាត្រា ១៥.- បណ្តាញនៃអង្គភាពប្រឆាំងអំពើពុករលួយ**

អង្គភាពប្រឆាំងអំពើពុករលួយ អាចមានការិយាល័យរបស់ខ្លួននៅគ្រប់រាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាបណ្តាញការងាររបស់ខ្លួន ។

ការិយាល័យប្រឆាំងអំពើពុករលួយ អនុវត្តការងាររបស់ខ្លួនក្រោមការដឹកនាំរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។ ការិយាល័យប្រឆាំងអំពើពុករលួយដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៣
## ថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

**មាត្រា ១៦.- ថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ**

ស្ថាប័នប្រឆាំងអំពើពុករលួយមានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការដែល

https://www.facebook.com/Voangeksa

ស្ថិតនៅក្នុងកញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ស្ថាប័នប្រឆាំងអំពើពុករលួយទទួលធនធានចាំបាច់នានាពីរាជរដ្ឋាភិបាលនិងមានសិទ្ធិទទួលធនធានវិភាគទាន ឬ ជំនួយពីអង្គការជាតិ អន្តរជាតិនានា ។ ស្ថាប័នប្រឆាំងអំពើពុករលួយមិនត្រូវទទួលជំនួយណាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាអាណាប័កទទួលសិទ្ធិ ។

ការគ្រប់គ្រង និង ចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## ការប្រកាសទ្រព្យសម្បត្តិ និង បំណុល

### មាត្រា ១៧.- សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល

ក្នុងពេលចូលកាន់មុខតំណែង និង ក្នុងពេលចេញពីមុខតំណែងបុគ្គលដូចខាងក្រោមនេះ ត្រូវប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ឬ ជាទម្រង់អេឡិចត្រូនិកទោះជាទ្រព្យសម្បត្តិនោះនៅក្រៅប្រទេសក្តី ឬ ក្នុងប្រទេសក្តី រួមទាំងបំណុលផង ហើយដាក់ជូនអង្គភាពប្រឆាំងអំពើពុករលួយដោយសាមីខ្លួនផ្ទាល់ :

១- សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង សមាជិករាជរដ្ឋាភិបាល ។

២- មន្ត្រីសាធារណៈដែលមានអាណត្តិជ្រើសតាំង ។

៣- សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធាន អនុប្រធាន និង មន្ត្រីទាំងអស់នៃអង្គភាពប្រឆាំងអំពើពុករលួយ ។

៤- មន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និង អ្នករាជការសាធារណៈផ្សេងទៀតដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ។

៥- មន្ត្រីផ្សេងទៀតដែលតែងតាំងដោយប្រកាសហើយត្រូវបានកំណត់ឱ្យប្រកាសទ្រព្យសម្បត្តិ និង បំណុលតាមបញ្ជីដែលរៀបចំឡើងដោយអង្គភាពប្រឆាំងអំពើពុករលួយ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ។

៦- ចៅក្រមអាសនៈ ចៅក្រមអយ្យការ សារការី ក្រឡាបញ្ជី និង អាជ្ញាសាលា ។

៧- ថ្នាក់ដឹកនាំនៃសង្គមស៊ីវិល ។

https://www.facebook.com/Voangeksa

**មាត្រា ១៨.- របបប្រកាសទ្រព្យសម្បត្តិ និង បំណុល**

មន្ត្រីដូចមានចែងក្នុងមាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) ខាងលើនេះ ត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុលរបស់ខ្លួនរៀងរាល់ ២ (ពីរ) ឆ្នាំម្តង នៅដើមខែមករា ហើយមិនឱ្យហួសពីថ្ងៃទី ៣១ ខែមករាឡើយ ។ ការប្រកាសទ្រព្យសម្បត្តិ និង បំណុលលើកដំបូងត្រូវអនុវត្តធ្វើ ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ក្រោយពេលចូលកាន់មុខតំណែង ។ ចំណែកការប្រកាសទ្រព្យសម្បត្តិ និង បំណុលលើកទីពីរ ត្រូវធ្វើនៅខែ មករា ឆ្នាំទី ៣ នៃការកាន់មុខតំណែង ហើយការប្រកាសទ្រព្យសម្បត្តិ និង បំណុលចុងក្រោយត្រូវធ្វើ ៣០ (សាមសិប) ថ្ងៃយ៉ាងយូរមុនពេលចាកចេញពីមុខតំណែង ។ ក្នុងករណីមិនអាចធ្វើការប្រកាសមុនពេលចាកចេញពីមុខតំណែងបានដោយមូលហេតុមានការដកហូតមុខតំណែង ត្រូវប្រកាសយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ក្រោយការចាកចេញពីមុខតំណែង។

ចំពោះបុគ្គលដែលមានសមាសភាពដូចមានចែងក្នុងមាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) ដែលកំពុងបំពេញមុខតំណែងត្រូវធ្វើការប្រ-កាសទ្រព្យសម្បត្តិ និង បំណុលលើកដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីស្ថាប័នប្រឆាំងអំពើពុករលួយបានបង្កើតឡើងដូចមានចែងក្នុងមាត្រា ៥៤ (ការរៀបចំដំណើរការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ) នៃច្បាប់នេះ ។

ទម្រង់បែបបទ និង នីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិ និង បំណុលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ។

**មាត្រា ១៩.- ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល**

ក្រោយពីត្រូវបានស៊ើបអង្កេត និង ទទួលសេចក្តីសម្រេចពីអង្គភាពប្រឆាំងអំពើពុករលួយ ជនដែលមានការពាក់ព័ន្ធនឹងអំពើពុករលួយត្រូវធ្វើការប្រកាសទ្រព្យសម្បត្តិ និង បំណុលរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ឬ ជាទម្រង់អេឡិចត្រូនិក ទោះបីជននោះពុំមានឈ្មោះក្នុងបញ្ជីប្រកាសទ្រព្យសម្បត្តិ និង បំណុលដូចមានចែងក្នុងមាត្រា ១៧ (សមាសភាព

https://www.facebook.com/Voangeksa

បុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) និង មាត្រា ១៨ (របបប្រកាសទ្រព្យសម្បត្តិនិងបំណុល) នៃច្បាប់នេះក៏ដោយ។

ការប្រកាសទ្រព្យសម្បត្តិ និង បំណុលរបស់ជនដែលជាប់ពាក់ព័ន្ធខាងលើនេះត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងមាត្រា ១៨ (របបប្រកាសទ្រព្យសម្បត្តិ និង បំណុល) នៃច្បាប់នេះរហូតពេលដែលអស់មានការចាំបាច់ ។

**មាត្រា ២០.- ការរក្សាទុកឯកសារប្រកាសទ្រព្យសម្បត្តិ និង បំណុល**

សំណុំឯកសារផ្ទាល់ខ្លួនម្នាក់ៗនៃអ្នកប្រកាសទ្រព្យសម្បត្តិ និង បំណុលត្រូវទុកជាការសម្ងាត់ខ្ពស់បំផុត និង ធ្វើជាទម្រង់អេឡិចត្រូនិកដោយមានលេខសម្ងាត់ ឬ ធ្វើជាលិខិតជាពីរច្បាប់តាមគំរូដែលកំណត់ដោយអង្គភាពប្រឆាំងអំពើពុករលួយ ហើយដាក់ក្នុងស្រោមសំបុត្រពីរដាច់ដោយឡែកពីគ្នា ដែលមួយច្បាប់រក្សាទុកដោយសាមីខ្លួន និង មួយច្បាប់ទៀតរក្សាទុកនៅអង្គភាពប្រឆាំងអំពើពុករលួយ ។ លើមាត់ស្រោមសំបុត្រដែលបិទជិតត្រូវប្រថាប់ត្រា និង ចុះហត្ថលេខាដោយប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ឬ តំណាងព្រមទាំងមានផ្តិតម្រាមដៃសាមីខ្លួនផង ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចធ្វើការសម្រេចបើកស្រោមសំបុត្រ ឬ បើកមើលឯកសារអេឡិចត្រូនិកខាងលើដើម្បីបុព្វហេតុនៃការស៊ើបអង្កេតតាមការចាំបាច់ ។

អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវរក្សាសំណុំឯកសារប្រកាសទ្រព្យសម្បត្តិ និង បំណុល ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ចាប់ពីពេលទទួលសំណុំឯកសារ ។

នីតិវិធីក្នុងការបើកស្រោមសំបុត្រ ឬ បើកមើលឯកសារអេឡិចត្រូនិកប្រកាសទ្រព្យសម្បត្តិ និង បំណុលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ។

## ជំពូកទី ៥

## នីតិវិធីអនុវត្តចំពោះបទល្មើសពុករលួយ និង អាជ្ញាធរមានសមត្ថកិច្ច

**មាត្រា ២១.- នីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសពុករលួយ**

នីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ

https://www.facebook.com/Voangeksa

និង បទល្មើសពុករលួយដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាពុំមានចែងនីតិវិធីដោយឡែកនៅក្នុងច្បាប់នេះទេ។

**មាត្រា ២២.- មន្ត្រីមានសមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតបទល្មើសពុករលួយ**

ប្រធាន អនុប្រធាន និង មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចស៊ើបអង្កេតលើបទល្មើសពុករលួយដែលមានចែងនៅក្នុងច្បាប់នេះ និង បទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

អង្គភាពផ្សេងទៀតដែលបានដឹងអំពីបទល្មើសពុករលួយទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ និងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌត្រូវប្ដឹងទៅអង្គភាព ឬ ការិយាល័យរាជធានី-ខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ។

**មាត្រា ២៣.- ការផ្ដល់នីតិសម្បទាចំពោះមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ**

ប្រធាន និង អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដោយពេញច្បាប់ ដើម្បីបំពេញមុខងាររបស់ខ្លួន ។

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយអាចទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចរៀបចំបញ្ជីឈ្មោះមន្ត្រី នៃអង្គភាពប្រឆាំងអំពើពុករលួយដែលត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៤.- សម្បថ**

ប្រធាន អនុប្រធាន និង មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្បថថាបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់តាមលំនាំសច្ចាប្រណិធានដែលមានចែងនៅក្នុងមាត្រា ៦៣ (សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ២៥.– អំណាចស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ**

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបទល្មើសពុករលួយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និង បទប្បញ្ញត្តិនៅក្នុងច្បាប់នេះ ។

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចស៊ើបអង្កេតបទល្មើសពុករលួយ ។ ក្នុងករណីស៊ើបអង្កេតបទល្មើសពុករលួយហើយរកឃើញបទល្មើសផ្សេងទៀតដែលមានអង្គហេតុទាក់ទិននឹងបទល្មើសដែលកំពុងស៊ើបអង្កេត មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ អាចធ្វើការស៊ើបអង្កេតបទល្មើសទាំងនោះរហូតចប់នីតិវិធី ។

អង្គភាពប្រឆាំងអំពើពុករលួយមិនអាចចាប់ផ្តើមការស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសពុករលួយបានទេ លើកលែងតែមានបញ្ជាពីអាជ្ញាធរតុលាការឱ្យអង្គភាពប្រឆាំងអំពើពុករលួយស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសពុករលួយ ។

តុលាការអាចបញ្ជាឱ្យអង្គភាពប្រឆាំងអំពើពុករលួយ ធ្វើកោសល្យវិច័យនានាដើម្បីជួយដល់ការវិនិច្ឆ័យរបស់តុលាការ ។

នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតទាំងនេះ និង ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា ៨៥ (អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង) មាត្រា ៩១ (ការឆែកឆេរ) មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង) និង មាត្រា ១១៤ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ឬ តំណាងដែលខ្លួនបានចាត់តាំងយ៉ាងត្រឹមត្រូវ មានតួនាទីដឹកនាំ សម្របសម្រួល និង ត្រួតពិនិត្យបេសកកម្មរបស់មន្ត្រីទាំងនេះជំនួសតួនាទីរបស់ព្រះរាជអាជ្ញារហូតដល់មានការឃាត់ខ្លួនជនសង្ស័យ ។

បន្ទាប់ពីមានការឃាត់ខ្លួន ព្រះរាជអាជ្ញាអនុវត្តអំណាចរបស់ខ្លួនដូចបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

នៅចុងបញ្ចប់នៃការស៊ើបអង្កេតនីមួយៗ អង្គភាពប្រឆាំងអំពើពុករលួយត្រូវបញ្ជូនរាល់កិច្ចនីតិវិធីទាំងអស់ទៅព្រះរាជអាជ្ញា ដើម្បីចាត់ការបន្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

https://www.facebook.com/Voangeksa

**មាត្រា ២៦.- បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ**

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចស្នើសុំពីអាជ្ញាធរឋានានុក្រមពាក់ព័ន្ធ ឱ្យផ្អាកជាបណ្ដោះអាសន្ននូវមុខងារនៃបុគ្គលទាំងឡាយណាដែលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជាប់ទាក់ទិននឹងរឿងហេតុនៃបទល្មើសពុករលួយ ។

ប្រសិនបើជនជាប់សង្ស័យរត់គេចខ្លួនទៅបរទេស ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចធ្វើបត្យាប័នតាមបទប្បញ្ញត្តិជាធរមាន ។

អង្គភាពប្រឆាំងអំពើពុករលួយអាចរៀបចំឱ្យមានទីកន្លែងមួយចំនួនជាអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្នសមស្រប សម្រាប់ការឃាត់ខ្លួនជននានាដែលធ្វើឡើងស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ នៅកន្លែងណាដែលអង្គភាពប្រឆាំងអំពើពុករលួយមិនអាចរៀបចំឱ្យមានទីកន្លែងជាអចិន្ត្រៃយ៍ឬជាបណ្ដោះអាសន្នសមស្របសម្រាប់ការឃាត់ខ្លួន អង្គភាពប្រឆាំងអំពើពុករលួយអាចសុំឱ្យស្ថាប័នមានសមត្ថកិច្ចរក្សាទុកជនដែលត្រូវបានអង្គភាពប្រឆាំងអំពើពុករលួយឃាត់ខ្លួន ។

**មាត្រា ២៧.- បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការតាមដាន**

ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍) និង មាត្រា ១៧២ (ការស្តាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលមានតម្រុយជាក់លាក់ថាមានបទល្មើសពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយអាច :

ក- ពិនិត្យ និង ដាក់ឱ្យស្ថិតក្រោមការឃ្លាំមើលនូវគណនីធនាគារ ឬ គណនីឯទៀតដែលចាត់ទុកដូចជាគណនីធនាគារ ។

ខ- ធ្វើការត្រួតពិនិត្យ និង បង្គាប់ឱ្យផ្តល់ឬចម្លងលិខិតយថាភូត ឬ លិខិតឯកជន ឬ ឯកសារធនាគារ ហិរញ្ញវត្ថុ និង ពាណិជ្ជកម្មទាំងអស់ ។

គ- តាមដាន ឃ្លាំមើល លបស្តាប់ លបថតសំឡេងនិងរូបភាព និង ដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់ និង ថត ។

ឃ- ចូលទៅពិនិត្យឯកសារនានា ព្រមទាំងឯកសាររក្សាទុកក្នុងប្រព័ន្ធអេឡិច-ត្រូនិក ។

https://www.facebook.com/Voangeksa

ង- រៀបចំប្រតិបត្តិការដែលមានគោលដៅប្រមូលភស្តុតាងជាក់ស្តែង ។

វិធានការខាងលើនេះ មិនត្រូវចាត់ទុកថាជាការរំលោភលើការសម្ងាត់វិជ្ជាជីវៈឡើយ ។ ការសម្ងាត់របស់ធនាគារក៏មិនមែនជាយុត្តិកម្មសម្រាប់បដិសេធមិនផ្តល់ភស្តុតាងពាក់ព័ន្ធនឹងបទល្មើសពុករលួយ ដែលមានបញ្ញត្តនៅក្នុងច្បាប់នេះឡើយ ។

**មាត្រា ២៨.- បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការបង្កកទ្រព្យសម្បត្តិរបស់បុគ្គល**

តាមការស្នើសុំរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រាជរដ្ឋាភិបាលអាចធ្វើអធិបញ្ញាឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូង បង្កកទ្រព្យសម្បត្តិរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងនៅក្នុងច្បាប់នេះ និងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

ទ្រព្យសម្បត្តិរបស់បុគ្គលដែលបានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ រាប់បញ្ចូលទាំងមូលនិធិដែលបានមក ឬ បង្កើតបានជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់បុគ្គលនោះ ។

**មាត្រា ២៩.- បុព្វសិទ្ធិរបស់អង្គភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសាធារណៈ**

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អាចធ្វើអធិបញ្ញាដល់អាជ្ញាធរសាធារណៈ មន្ត្រីរាជការ ពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត ព្រមទាំងបណ្តាអង្គ-ភាពនៃវិស័យឯកជនពាក់ព័ន្ធមានជាអាទិ៍ស្ថាប័នហិរញ្ញវត្ថុធ្វើកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីនៃអង្គភាពក្នុងការងារស៊ើបអង្កេត ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយក៏អាចស្នើសុំការសហការពីស្ថាប័នជាតិ និងអន្តរជាតិក្នុងការធ្វើកោសល្យវិច័យនានាទាក់ទងទៅនឹងការស៊ើបអង្កេតរបស់ខ្លួនផងដែរ ។

**មាត្រា ៣០.- ការចាប់យក**

ការចាប់យកត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៣១.- នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ**

នៅក្នុងរឿងក្តីព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទល្មើសពុករលួយ តុលាការដែលបានទទួលបណ្តឹង ត្រូវធ្វើការបើកសវនាការជំនុំជម្រះយ៉ាងឆាប់បំផុត ។

## ជំពូកទី ៦
## បទល្មើសពុករលួយ និង ទោស

### មាត្រា ៣២.- បទល្មើសពុករលួយដែលមានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌ

ក្រៅពីបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ បទល្មើសដែលមានចែងនៅក្នុង មាត្រា ២៧៨ (បទស៊ីសំណូកនៃនិយោជិត) មាត្រា ២៧៩ (បទសូកប៉ាន់ដល់និយោជិត) មាត្រា ២៨០ (បទស៊ីសំណូករបស់អភិបាលជាអាទិ៍) មាត្រា ២៨៣ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៣៨៧ (បទដេញថ្លៃមិនត្រឹមត្រូវ) មាត្រា ៤០៤ (និយមន័យនៃការសម្លាតប្រាក់) មាត្រា ៤០៥ (ទោសដែលត្រូវអនុវត្ត) មាត្រា ៤០៦ (ស្ថានទម្ងន់ទោស) មាត្រា ៤០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៥១៧ (បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម) មាត្រា ៥១៨ (បទសូកប៉ាន់ចំពោះចៅក្រម) មាត្រា ៥១៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៥៤៧ (បទស៊ីសំណូករបស់សាក្សីដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ) មាត្រា ៥៤៨ (បទសូកប៉ាន់សាក្សី) មាត្រា ៥៥៣ (បទស៊ីសំណូករបស់អ្នកបកប្រែ) មាត្រា ៥៥៤ (បទសូកប៉ាន់អ្នកបកប្រែ) មាត្រា ៥៥៥ (បទស៊ីសំណូករបស់អ្នកជំនាញ) មាត្រា ៥៥៦ (បទសូកប៉ាន់អ្នកជំនាញ) មាត្រា ៥៥៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៥៩២ (និយមន័យនៃវិតិក្រម) មាត្រា ៥៩៣ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៤ (បទស៊ីសំណូក) មាត្រា ៥៩៥ (និយមន័យនៃជំនួញឥទ្ធិពលអកម្ម) មាត្រា ៥៩៦ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៧ (និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់) មាត្រា ៥៩៨ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៩ (និយមន័យនៃបក្ខានុគ្រោះ) មាត្រា ៦០០ (ទោសដែលត្រូវអនុវត្ត) មាត្រា ៦០១ (បទបំផ្លាញដោយចេតនា និងគៃបំបាត់ដោយទុច្ចរិត) មាត្រា ៦០៥ (បទសូកប៉ាន់) មាត្រា ៦០៦ (បទជំនួញឥទ្ធិពលសកម្ម) មាត្រា ៦០៧ (បទសម្លុតគំរាម) មាត្រា ៦០៨ (បទបំផ្លាញនិងគៃបំបាត់) មាត្រា ៦២៥ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៦៣៧ (បទស៊ីសំណូកដោយអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៣៨ (បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៣៩ (បទស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៤០ (បទសូកប៉ាន់

ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៤១ (ការអនុវត្តបទមជ្ឈិមនៃមាត្រា ៦៣៩ និង មាត្រា ៦៤០ ចំពោះគ្រប់វិជ្ជាជីវៈខាងវេជ្ជសាស្ត្រ) និង មាត្រា ៦៤៤ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌជាបទល្មើសពុករលួយដែលត្រូវអនុវត្តតាមច្បាប់នេះ ។

**មាត្រា ៣៣.– បទស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ អំពើប្រព្រឹត្តដោយមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈដែលសុំទាមទារ ឬ យល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬ ដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយដើម្បី ៖

១- បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

២- មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

**មាត្រា ៣៤.– បទសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណាដែលគ្មានសិទ្ធិដោយផ្ទាល់ ឬ ដោយប្រយោលប្រគល់អំណោយ ឬ ជំនូន ឬ ធ្វើការសន្យាជាមួយ ឬ ផ្តល់អត្ថប្រយោជន៍អ្វីមួយដល់មន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈដើម្បីឱ្យមន្ត្រីនោះ ៖

១- បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

២- មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

**មាត្រា ៣៥.– បទរំលោភអំណាច**

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅក្នុងការបំពេញមុខងាររបស់ខ្លួន ឬ ក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការរារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ)

https://www.facebook.com/Voangeksa

ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព ។

**មាត្រា ៣៦.– បទមានទ្រព្យសម្បត្តិដោយខុសច្បាប់**

ការមានទ្រព្យសម្បត្តិដោយខុសច្បាប់ គឺជាកំណើនទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលបុគ្គលនោះមិនអាចផ្តល់ការពន្យល់សមហេតុសមផលនូវការកើនឡើងនៃទ្រព្យសម្បត្តិនេះដោយប្រៀបធៀបទៅនឹងចំណូលស្របច្បាប់របស់ខ្លួន ។

បន្ទាប់ពីបានធ្វើការប្រកាសទ្រព្យសម្បត្តិ និង បំណុលលើកមុន គ្រប់បុគ្គលដូចមានចែងនៅក្នុង មាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) និង មាត្រា ១៨ (ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) នៃច្បាប់នេះ ដែលមិនអាចផ្តល់ការពន្យល់សមហេតុសមផលនូវការកើនឡើងនៃទ្រព្យសម្បត្តិនេះ ដោយប្រៀបធៀបទៅនឹងចំណូលស្របច្បាប់របស់ខ្លួន ត្រូវទទួលរងនូវការរឹបអូសទ្រព្យសម្បត្តិដែលពុំអាចពន្យល់បានទាំងអស់ ទុកជាសម្បត្តិរដ្ឋ ។

ប្រសិនបើទ្រព្យសម្បត្តិដែលកើនដោយពុំអាចពន្យល់បាននេះ មានការពាក់ព័ន្ធនឹងបទល្មើសពុករលួយណាមួយដូចមានចែងក្នុងច្បាប់នេះ ម្ចាស់ទ្រព្យសម្បត្តិត្រូវទទួលទោសដែលមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៧.– បទទទួលផលបន្តពីបទល្មើសពុករលួយ**

អំពើទទួលផលបន្តពីបទល្មើសពុករលួយ គឺជាអំពើលាក់បំបាំង រក្សាទុក ឬ ជញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះបានមកពីបទល្មើសពុករលួយ ដូចមានចែងនៅក្នុងច្បាប់នេះ ។ ត្រូវចាត់ទុកជាអំពើទទួលផលបន្តពីបទល្មើសពុករលួយផងដែរចំពោះ :

១- អំពើធ្វើជាអន្តរការី ដើម្បីបញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះបានមកពីបទល្មើសពុករលួយ ។

២- អំពើដែលបានទទួលប្រយោជន៍ពីផលបន្តពីបទល្មើសពុករលួយដោយបានដឹងហេតុការណ៍ច្បាស់ ។

https://www.facebook.com/Voangeksa

អំពើទទួលផលបន្តពីបទល្មើសពុករលួយត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

អំពើទទួលផលបន្តពីបទល្មើសពុករលួយត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តឡើង ៖

១- ជាទម្លាប់ ។

២- ដោយប្រើប្រាស់ភាពងាយស្រួលដែលទទួលបានពីសកម្មភាពវិជ្ជាជីវៈផ្ដល់ឱ្យ ។

៣- ជាក្រុមមានការចាត់តាំង ។

**មាត្រា ៣៨.– បទមិនប្រកាសទ្រព្យសម្បត្តិ និង បំណុល**

ជនណាដែលមិនបានប្រកាសទ្រព្យសម្បត្តិនិងបំណុល ឬ បានប្រកាសមិនត្រឹមត្រូវនូវទ្រព្យសម្បត្តិរបស់ខ្លួនទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) មាត្រា ១៨ (របបប្រកាសទ្រព្យសម្បត្តិ និង បំណុល) និង មាត្រា ១៩ (ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ហើយត្រូវបានបង្ខិតឱ្យធ្វើការប្រកាសទ្រព្យសម្បត្តិជូនអង្គភាពប្រឆាំងអំពើពុករលួយ ។ ក្នុងករណីរឹងរូសមិនព្រមប្រកាសទ្រព្យសម្បត្តិទៀតត្រូវផ្ដន្ទាទោសទ្វេដង ។

ដោយឡែកចំពោះថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចរំលឹកជាលាយលក្ខណ៍អក្សរដល់ថ្នាក់ដឹកនាំនៃអង្គការសង្គមស៊ីវិល មុននឹងអនុវត្តមាត្រានេះ ។

**មាត្រា ៣៩.– បទធ្វើឱ្យបាត់ការសម្ងាត់នៃប្រភពព័ត៌មានស្ដីពីអំពើពុករលួយ**

ជនណាដែលធ្វើឱ្យបាត់ការសម្ងាត់នៃប្រភពព័ត៌មានស្ដីពីអំពើពុករលួយ ត្រូវផ្ដន្ទា

https://www.facebook.com/Voangeksa

ទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការរក្សាការសម្ងាត់ដាច់ខាត មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

**មាត្រា ៤០.‒ បទរារាំង និង ការបង្អាក់បង្អង់ដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ**

អ្នករាជការសាធារណៈ យោធិន នគរបាលជាតិ ពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត មន្ត្រីសង្គមស៊ីវិល មន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ ដែលធ្វើការសម្លុតគំរាមកំហែង រារាំង ឬ ជ្រៀតជ្រែកក្នុងការបំពេញមុខងាររបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤១.‒ បទប្ដឹងបរិហារដោយភូតកុហក**

អំពើប្ដឹងបរិហារដោយភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយឬតុលាការនូវអង្គហេតុបទល្មើសពុករលួយ កាលបើអំពើនេះនាំឱ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៤២.‒ បទចំពាសលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក**

បុគ្គលណាដែលគ្មានសិទ្ធិធ្វើការផ្ទេរ ធ្វើអនុប្បទាន ឬ ធ្វើការដោះដូរនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យកដោយរំលោភលើបទប្បញ្ញត្តិនៃមាត្រា ៣០ (ការចាប់យក) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៣.‒ បទល្មើសពុករលួយតូចតាចនិងទោស**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ៥ (ប្រាំ) ឆ្នាំ ជនណាដែលប្រព្រឹត្តបទល្មើសពុករលួយដែលបញ្ញត្តនៅក្នុងច្បាប់នេះ ហើយបានបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម :

https://www.facebook.com/Voangeksa

- បទល្មើសប្រព្រឹត្តឡើងសម្រាប់ជីវភាពប្រចាំថ្ងៃ
- បទល្មើសប្រព្រឹត្តឡើងមានលក្ខណៈតូចតាច
- បទល្មើសដែលមិនបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គមជាតិ
- មានការវាយតម្លៃទទួលស្គាល់ពីអង្គភាពប្រឆាំងអំពើពុករលួយថាជាបទល្មើសពុករលួយតូចតាច ។

**មាត្រា ៤៤.‒ ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដូចមានចែងនៅក្នុងមាត្រា ២៧៨ (បទស៊ីសំណូកនៃនិយោជិត) មាត្រា ២៧៩ (បទសូកបាន់ដល់និយោជិត) មាត្រា ៣៨៧ (បទបេញ្ញថ្លៃមិនត្រឹមត្រូវ) មាត្រា ៤០៤ (និយមន័យនៃការសំអាតប្រាក់) មាត្រា ៤០៥ (ទោសដែលត្រូវអនុវត្ត) មាត្រា ៤០៦ (ស្ថានទម្ងន់ទោស) មាត្រា ៥៩២ (និយមន័យនៃវិតិក្រម) មាត្រា ៥៩៣ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៧ (និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់) មាត្រា ៥៩៨ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៩ (និយមន័យនៃបក្ខានុគ្រោះ) មាត្រា ៦០០ (ទោសដែលត្រូវអនុវត្ត) មាត្រា ៦៣៨ (បទសូកបាន់ចំពោះអ្នកមាននីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៤០ (បទសូកបាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៣៩ (បទរំលោភអំណាច) និង មាត្រា ៤០ (បទរារាំង និង ការជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ) នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមបានសម្រេចដែរ ។

**មាត្រា ៤៥.‒ ទោសបន្ថែមអនុវត្តចំពោះបទល្មើសពុករលួយ**

ចំពោះបទល្មើសពុករលួយដូចមានចែងនៅក្នុងច្បាប់នេះ ទោសបន្ថែមមួយ ឬ ច្រើនដូចខាងក្រោម អាចត្រូវបានប្រកាសពី :

១- ការដកសិទ្ធិពលរដ្ឋខ្លះជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

២- ការហាមឃាត់ចំពោះការប្រកបមុខរបរជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបមុខរបរ ឬ ក្នុងឱកាសនៃការប្រកបមុខរបរនេះ ។

https://www.facebook.com/Voangeksa

៣- ការហាមឃាត់នូវការស្នាក់អាស្រ័យនៅសម្រាប់រយៈពេលមិនលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទល្មើសឧក្រិដ្ឋ និង សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ចំពោះបទល្មើសមជ្ឈិម ។

៤- ការហាមឃាត់ជនបរទេសនូវការចូលមក និង ស្នាក់អាស្រ័យនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

៥- ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦- ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាទីដៅនៃបទល្មើស ។

៧- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨- ការរឹបអូសនូវឧបភោគភណ្ឌសម្ភារៈ និង គ្រឿងសង្ហារិមតែងលំអទីតាំងដែលក្នុងទីតាំងនោះ បទល្មើសត្រូវបានប្រព្រឹត្ត។

៩- ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១០- ការហាមឃាត់ចំពោះការកាន់កាប់ ឬ យកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១១- ការបិទគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបទល្មើស ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១២- ការហាមឃាត់ការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកជាសាធារណៈ ឬ ដែលប្រើប្រាស់ដោយសាធារណជនជាស្ថាពរឬសម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១៣- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេលមិនលើសពី ២ (ពីរ) ខែ ។

១៥- ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ។

១៦- ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេលមិនលើសពី ៨ (ប្រាំបី) ថ្ងៃ ។

https://www.facebook.com/Voangeksa

**មាត្រា ៤៦.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើសពុករលួយដែលមានចែងក្នុងមាត្រា ៣៧ (បទទទួលផលបន្តពីបទល្មើសពុករលួយ) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល និង ត្រូវទទួលទោសបន្ថែមមួយ ឬ ច្រើនដូចខាងក្រោមនេះ :

១- ការរំលាយចោល។

២- ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។

៦- ការហាមឃាត់ចំពោះការចេញមូលប្បទានបត្រក្រៅពីមូលប្បទានបត្រដែលបញ្ជាក់ដោយធនាគារណាមួយ ។

៧- ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់។

៨- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស ។

៩- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬ ដែលបានប្រើប្រាស់ដោយសាធារណជន ។

១០- ការរឹបអូសឧបករណ៍សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១- ការរឹបអូសនូវវត្ថុឬមូលនិធិដែលជាទីដៅនៃបទល្មើស ។

១២- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣- ការរឹបអូសនូវឧបភោគភណ្ឌ សម្ភារៈ និង ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤- ការបិទផ្សាយនៃសេចក្តីសម្រេចផ្តន្ទាទោស ។

១៥-ការចេញផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ឬ ផ្សព្វផ្សាយតាមមធ្យោបាយគមនាគមន៍សោតទស្សន៍ ។

https://www.facebook.com/Voangeksa

**មាត្រា ៤៧.– ការផ្សព្វផ្សាយបញ្ចេញនូវកំណត់ត្រារបស់ធនាគារ**

គ្រឹះស្ថានឥណទាន ឬ ស្ថាប័នហិរញ្ញវត្ថុរួចផុតពីការទទួលខុសត្រូវទាំងអស់ ហើយគ្មានបណ្ដឹងព្រហ្មទណ្ឌណាមួយត្រូវបានធ្វើប្រឆាំងនឹងអ្នកដឹកនាំ ឬ អាណត្តិនៃគ្រឹះស្ថាន ឬ ស្ថាប័ននោះឡើយ ប្រសិនបើប្រតិបត្តិការនោះត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិច្បាប់ លើកលែងតែក្នុងករណីដែលរកឃើញថាមានការព្រមព្រៀងគ្នាជាមុន ដើម្បីរៀបចំបន្លំជាមួយម្ចាស់ប្រាក់ ឬ អ្នកធ្វើប្រតិបត្តិការ ។

**មាត្រា ៤៨.– សេចក្ដីសម្រេចរឹបអូស**

នៅពេលដែលបុគ្គលណាមួយត្រូវបានផ្ដន្ទាទោសពីបទល្មើសពុករលួយ តុលាការត្រូវសម្រេចរឹបអូសផលនៃអំពើពុករលួយទាំងអស់ដែលរួមមាន ទ្រព្យសម្បត្តិ សម្ភារៈ និងឧបករណ៍ទាំងអស់ដែលជាកម្មវត្ថុនៃអំពើពុករលួយទុកជាសម្បត្តិរដ្ឋ ។

ប្រសិនបើផលនៃអំពើពុករលួយខាងលើត្រូវបានបំប្លែងទៅជាទ្រព្យសម្បត្តិផ្សេងពីសភាពដើម ទ្រព្យសម្បត្តិដែលត្រូវបានបំប្លែងនេះក៏ត្រូវក្លាយជាកម្មវត្ថុនៃការរឹបអូសដល់ទីកន្លែងដែលទ្រព្យសម្បត្តិនេះតាំងនៅផងដែរ ។

ប្រសិនបើផលនៃអំពើពុករលួយនេះបង្កើតឱ្យមានជាចំណូល ឬ ផលដទៃផ្សេងទៀត ចំណូល និង ផលទាំងនេះក៏ត្រូវរឹបអូសផងដែរ ។

ប្រសិនបើផលទាំងនោះរលាយបាត់ ឬ បាត់បង់តម្លៃ តុលាការអាចបញ្ជាឱ្យទូទាត់តម្លៃដើមនៃផលទាំងនោះ ។

**មាត្រា ៤៩.– ការទាមទារឱ្យបញ្ជូននូវផលនៃបទល្មើសពុករលួយ**

នៅក្នុងករណីដែលរកឃើញថាទ្រព្យសម្បត្តិ និង ផលនៃអំពើពុករលួយត្រូវបានរក្សាទុកនៅក្នុងរដ្ឋបរទេស អាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាត្រូវចាត់វិធានការដើម្បីទាមទារយកទ្រព្យសម្បត្តិ និង ផលទាំងនោះមកកម្ពុជាវិញតាមមធ្យោបាយនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ។ ព្រះរាជាណាចក្រកម្ពុជាក៏ត្រូវធ្វើសហប្រតិបត្តិការជាមួយប្រទេសដទៃដែលលើកសំណើសុំបញ្ជូនទៅវិញនូវផលនៃបទល្មើសពុករលួយ ដែលត្រូវបានរក្សាទុកក្នុងប្រទេសកម្ពុជា ។

https://www.facebook.com/Voangeksa

## ជំពូកទី ៧
## បត្យាប័ន និង ជំនួយផ្នែកច្បាប់ទៅវិញទៅមក

### មាត្រា ៥០.- បទប្បញ្ញត្តិដែលត្រូវអនុវត្តចំពោះបត្យាប័ន

បទប្បញ្ញត្តិនៃជំពូកទី ២ មាតិកាទី ១ គន្ថីទី ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងរឿងបត្យាប័នពាក់ព័ន្ធនឹងបទល្មើសពុករលួយ ។

### មាត្រា ៥១.- ជំនួយផ្នែកច្បាប់ទៅវិញទៅមក

ក្នុងករណីបទល្មើសពុករលួយ អាជ្ញាធរតុលាការនៃព្រះរាជាណាចក្រកម្ពុជាអាចប្រគល់អំណាចឱ្យទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃរដ្ឋបរទេសណាមួយ និង អាចទទួលអំណាចពីអាជ្ញាធរតុលាការនៃរដ្ឋបរទេសណាមួយដែរដើម្បី :

១- ប្រមូលយកសក្ខីភាព ឬ យកចម្លើយដែលឆ្លើយតាមផ្លូវតុលាការ ។

២- ឱ្យដំណឹងពីលិខិតផ្សេងៗរបស់តុលាការ ។

៣- ធ្វើការឆែកឆេរ ឃាត់ទុក និង ដកហូត ។

៤- ធ្វើការពិនិត្យវត្ថុ និង ទីកន្លែង ។

៥- ផ្តល់ព័ត៌មាន និង វត្ថុតាង ។

៦- ផ្តល់ឯកសារកំណត់ហេតុជាច្បាប់ដើម ឬ សេចក្តីចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃឯកសារ និង សំណុំរឿង រាប់ទាំងសេចក្តីស្រង់បញ្ជីប្រាក់ពីធនាគារ ឯកសារគណនេយ្យ សំណុំរឿងរបស់ក្រុមហ៊ុន និង ឯកសារពាណិជ្ជកម្មព្រមទាំងលិខិតយថាភូត ឬ លិខិតឯកជន ។

៧- បង្ហាញ ឬ ផ្តល់សាក្សី អ្នកជំនាញ ឬ ជនឯទៀតរាប់ទាំងជនជាប់ឃុំខ្លួនផងដែលយល់ព្រមជួយក្នុងការស៊ើបអង្កេត ឬ យល់ព្រមចូលរួមក្នុងនីតិវិធី ។

៨- កំណត់អត្តសញ្ញាណ ឬ ស្រាវជ្រាវរកផលបាន ទ្រព្យសម្បត្តិ បរិក្ខារ និង សម្ភារៈទាំងឡាយដែលបានមកពីការប្រព្រឹត្តបទល្មើស និង មធ្យោបាយបទល្មើស ។

៩- ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផល និង ទ្រព្យសម្បត្តិដែលបានមកពីបទល្មើសពុករលួយព្រមទាំងបរិក្ខារ សម្ភារៈដែលប្រើប្រាស់ ឬ ទុកសម្រាប់ប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសពុករលួយ ។

https://www.facebook.com/Voangeksa

១០- ចាត់ឱ្យអនុវត្តសេចក្តីសម្រេចដែលបញ្ជាឱ្យធ្វើការរឹបអូស ដកហូត ឬ យកមកវិញនូវផលិតផល ទ្រព្យសម្បត្តិ បរិក្ខារ សម្ភារៈទាំងឡាយដែលបានមកពីការប្រព្រឹត្តអំពើពុករលួយ ។

១១- បញ្ជាឱ្យធ្វើការរឹបអូសវត្ថុទាំងឡាយដែលមានចែងក្នុងចំណុចខាងលើ ។

១២- ឱ្យដំណឹងអំពីការចោទប្រកាន់តាមនីតិវិធីព្រហ្មទណ្ឌ ។

១៣- សួរចម្លើយជនត្រូវចោទតាមនីតិវិធីព្រហ្មទណ្ឌ ។

១៤- រកឱ្យឃើញ និង កំណត់អត្តសញ្ញាណសាក្សី និង ជនសង្ស័យ ។

**មាត្រា ៥២.- ករណីពលរដ្ឋខ្មែរដែលមានសញ្ជាតិលើសពីមួយ**

ស្ថាប័នប្រឆាំងអំពើពុករលួយ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ មានភារកិច្ចស្វះស្វែងរកកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ជំនួយផ្នែកច្បាប់ទៅវិញទៅមកអំពីស្ថានភាពទ្រព្យសម្បត្តិរបស់ពលរដ្ឋខ្មែរដែលមានសញ្ជាតិលើសពីមួយ ។

**មាត្រា ៥៣.- នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមក**

នីតិវិធីនៃការអនុវត្តជំនួយផ្នែកច្បាប់ទៅវិញទៅមក ត្រូវអនុវត្តតាមគោលការណ៍ទាំងឡាយដែលបានកំណត់ក្នុងសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី និង ច្បាប់ជាតិជាធរមាន ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៤.- ការរៀបចំដំណើរការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ**

បន្ទាប់ពីច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ យ៉ាងយូរ ។

https://www.facebook.com/Voangeksa

អង្គភាពដើម្បីប្រឆាំងអំពើពុករលួយ ត្រូវទទួលបន្តអនុវត្តភារកិច្ចប្រឆាំងអំពើពុករលួយតាមច្បាប់ជាធរមាន និង ផ្សព្វផ្សាយច្បាប់នេះរហូតដល់ស្ថាប័នប្រឆាំងអំពើពុករលួយត្រូវបានរៀបចំហើយ ទើបអង្គភាពដើម្បីប្រឆាំងអំពើពុករលួយនេះត្រូវរំលាយ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៥៥.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៦.- ការប្រកាសឱ្យប្រើច្បាប់**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

**មាត្រា ៥៧.- ការអនុវត្តច្បាប់**

បន្ទាប់ពីការចូលជាធរមាននៃច្បាប់នេះ បទប្បញ្ញត្តិផ្សេងពីបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ ត្រូវយកមកអនុវត្តភ្លាម ។

បទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ មានអានុភាពអនុវត្តក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ក្រោយពេលដែលក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តទាំងស្រុង ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០

នស/រកម.០៤១០.០០៦

[ហត្ថលេខា]

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**

[ហត្ថលេខា]

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

[ហត្ថលេខា]

**សុខ អាន**